# របាយការណ៍សង្ខេប
# ស្តីពី
# "វឌ្ឍនភាព និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តមណ្ឌលគិរី"
# ក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការគណៈរដ្ឋមន្ត្រី
# ឯកឧត្តម ម៉ែន វ៉ុយ ប្រធានក្រុមប្រឹក្សាខេត្តមណ្ឌលគិរី

(ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២)

## អ រ គុ ណ ស ន្តិ ភា ព !

**ជាបឋម ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ**

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ !
- សូមក្រាបបង្គំទូលថ្វាយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម **សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !
- សូមក្រាបបង្គំទូលថ្វាយ សម្តេចព្រះមហាក្សត្រី នរោត្តម **មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !
- សូមគោរព សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភាជាតិ និង **លោកជំទាវ** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាជាតិ និង សម្តេចធម្មវិសុទ្ធវង្សា **សៅ ទី ហេង សំរិន** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង **លោកជំទាវ** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ព្រមទាំងសហការី ***ជាទីគោរពដ៏ខ្ពង់ខ្ពស់ !***
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បងប្អូនអ្នកសារព័ត៌មានជាតិ អន្តរជាតិ ព្រមទាំង សមាជិក សមាជិក ទាំងអស់ ដែលមានវត្តមាននៅក្នុងអង្គសន្និសីទសារព័ត៌មាន នាពេលនេះ ***ជាទីមេត្រី !***
- បងប្អូនប្រជាពលរដ្ឋ និងជនរួមជាតិ ដែលបាន និងកំពុងតាមដានទស្សនាការផ្សាយផ្ទាល់សន្និសីទសារព័ត៌មានស្តីពីវឌ្ឍនភាព និងទិសៅការងារអនុវត្តបន្តរបស់រដ្ឋបាលខេត្តមណ្ឌលគិរី នាឱកាសនេះ ***ជាទីគោរពស្រលាញ់រាប់អាន !***

ជាបឋម ជំនួសមុខឱ្យក្រុមប្រឹក្សា គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋខេត្តមណ្ឌលគិរី និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំបាទមានបេតិសោមនស្សរីករាយយ៉ាងក្រៃលែង និងមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយបានចូលរួមនៅក្នុងសន្និសីទសារព័ត៌មាន ដែលបានរៀបចំឡើង ដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **ផៃ ស៊ីផាន**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មានស្តីពី **"វឌ្ឍនភាពមូលដ្ឋាន ឃុំ/សង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តមណ្ឌលគិរី"** នេះឡើង និងបានផ្តល់ឱកាសឱ្យខ្ញុំបាទបានចូលរួមជាវាគ្មិន ដើម្បីបង្ហាញជូនសាធារណជនឱ្យបានយល់ជ្រួតជ្រាបអំពីវឌ្ឍនភាព ការអភិវឌ្ឍរីកចម្រើន និងទិសដៅការងារបន្តរបស់ខេត្តមណ្ឌលគិរី ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់និងឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ ទន្ទឹមនឹងនោះដែរ សូមអរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គសន្និសីទដ៏មានសារសំខាន់ នាពេលនេះ ។

ក្នុងនាមក្រុមប្រឹក្សា គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទាំងអស់នៅក្នុងខេត្តមណ្ឌលគិរី ខ្ញុំសូមយកឱកាសនេះ សម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែង និងយកជីវិតធ្វើជាដើមទុនក្នុងការនាំយកមកវិញនូវសុខសន្តិភាពជូនប្រទេសជាតិ និងពលរដ្ឋកម្ពុជា **"សូមអរគុណសន្តិភាព"** ដែលធ្វើឲ្យប្រទេសជាតិមានស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍលើគ្រប់វិស័យទាំងពេលបច្ចុប្បន្ន និងទៅអនាគត ។

ដោយអនុវត្តតាមគោលនយោបាយដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងមានកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ជាគោល មានផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងផែនការវិនិយោគ៣ឆ្នាំរំកិល ដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្ត សម្រាប់ជាត្រីវិស័យ ក្នុងការអនុវត្តការងារ នៅក្នុងឆ្នាំ២០២១នេះ រដ្ឋបាលខេត្តមណ្ឌលគិរី បានអនុវត្តការងារ និងសម្រេចបាននូវសមិទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម ៖

### ❖ អំពីភូមិសាស្ត្រ និងប្រជាសាស្ត្រខេត្តមណ្ឌលគិរី

ខេត្តមណ្ឌលគិរី ស្ថិតនៅភូមិភាគឥសាន្ត នៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ **៣៨២ គីឡូម៉ែត្រ** ពីរាជធានីភ្នំពេញ ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ប្រជុំភ្នំ ខ្ពង់រាប សំបូរដោយជ្រោះជ្រងជ្រលងដងអូរ គិរីបព្វតាជាច្រើន និងជាខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម មានព្រំប្រទល់ ៖

- ខាងលិចទល់នឹង ខេត្តក្រចេះ
- ខាងជើងទល់នឹង ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី
- ខាងកើត និងខាងត្បូងទល់នឹង ខេត្តដាក់ឡាក់ ខេត្តដាក់ណុង និងខេត្តបិញភឿក នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រវែង **៣១៤.៦៦៤ គីឡូម៉ែត្រ** ។
- ផ្ទៃដីខេត្តសរុប មានទំហំ **១៤ ២៨៨ គ.ម²** ។
- មាន ក្រុង១ និងស្រុក៤ ឃុំ១៧ សង្កាត់ចំនួន ០៤ និងភូមិចំនួន ៩២ភូមិ ។
- ប្រជាពលរដ្ឋសរុប **៩៣ ៤៤១នាក់** ស្រី **៤៥ ៤២៥នាក់** ស្មើនឹង **២២ ២២០គ្រួសារ** អ្នកដែលមានអាយុ ១៨ឆ្នាំឡើង **៥១ ៤៣១នាក់** និងមានដង់ស៊ីតេ **៧នាក់ ក្នុង ១គីឡូម៉ែត្រ** ។

- ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចនៅទូទាំងខេត្តមានចំនួន **៥៣ ៤៤៤នាក់** ស្មើនឹង **៥៧,២០%** នៃប្រជាជនសរុប ដែលមានចំនួន ០៨ជនជាតិ ក្នុងនោះរួមមាន ព្នង ក្រោល គ្រឹង ស្ទៀង ទំពួន ចារាយ ថ្មូន និងកួយ ។
- ប្រជាពលរដ្ឋមានមុខរបរចម្បងក្នុងវិស័យកសិកម្ម **៨២,%** វិស័យសិប្បកម្ម **១%** និងវិស័យសេវាកម្ម **១៧ %**។
- មានច្រកទ្វារព្រំដែនទ្វេភាគីសំខាន់ៗចំនួន០៣ សម្រាប់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយប្រទេសវៀតណាម ក្នុងនោះមាន ៖ ច្រកទ្វារទ្វេភាគីឡាប៉ាខេ ស្រុកកែវសីមា , ច្រកទ្វារទ្វេភាគីដាក់ដាំ ស្រុកអូររាំង និងច្រកទ្វារទ្វេភាគីណាំលៀរ ស្រុក ពេជ្រាដា។ ដោយឡែកច្រកទ្វារដើមមៀត ស្រុកកោះញែក មិនទាន់ដំណើរការនៅឡើយ ព្រោះគ្មានផ្លូវ។

**សក្តានុពលសេដ្ឋកិច្ចសំខាន់ៗរបស់ខេត្តមាន ៖**

- វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ៖ ផ្ទៃដីមានទំហំធំ ដីមានជីជាតិអំណោយផលដល់ការដាំដុះដំណាំកសិកម្ម និងដំណាំកសិ-ឧស្សាហកម្ម ក្នុងនោះ យើងមានផ្ទៃដីអាចដាំដុះដំណាំស្រូវ នៅស្រុកកោះញែក ផ្ទៃដីដាំដុះដំណាំផ្សេងៗនៅក្រុងសែនមនោរម្យ ស្រុកកែវសីមា ស្រុកពេជ្រាដា និងស្រុកអូររាំង ជាដើម។ល។ ទន្ទឹមនឹងនោះដែរ ផ្ទៃដីខេត្តមណ្ឌលគិរីក៏បានបង្កភាពងាយស្រួលដល់បណ្តាក្រុមហ៊ុន ក្នុងការធ្វើវិនិយោគក្នុងខេត្ត ជាក់ស្តែង រហូតដល់បច្ចុប្បន្ននេះ មានក្រុមហ៊ុនកំពុងធ្វើការវិនិយោគក្នុងខេត្តចំនួន **២៥ក្រុមហ៊ុន** លើផ្ទៃដី **១៤៧.០១៣,០៥ហិកតា** ។ ដំណាំកៅស៊ូ នៅទូទាំងខេត្តសរុបចំនួន **៤២.៥៣៧,៤១ហិកតា** ក្នុងនោះ កៅស៊ូក្រុមហ៊ុន ៣១.២៣១,៩៨ ហិកតា , កៅស៊ូគ្រួសារ **១១.៣០៥,៤៣ហិកតា** ។
- វិស័យអេកូទេសចរណ៍ ៖ មានតំបន់រមណីយដ្ឋានទេសចរណ៍វប្បធម៌ និងធម្មជាតិក្នុងខេត្តសរុបចំនួន ១០៥កន្លែង ក្នុងនោះ តំបន់រមណីយដ្ឋានទេសរណ៍ ដែលភ្ញៀវទេសចរអាចទៅដល់ចំនួន ៣៦កន្លែង ក្នុងនោះ រមើយដ្ឋានមានសេវាកម្មស្នាក់នៅចំនួន ៣២ កន្លែង ស្មើនឹង ៥៩៥បន្ទប់ និងរមើយដ្ឋានគ្មានសេវាកម្មស្នាក់នៅចំនួន ០៤កន្លែង, មានសេវាកម្មទេសចរណ៍ ក្នុងនោះ មាន សណ្ឋាគារ ០៧ កន្លែង ស្មើនឹង ៣០២បន្ទប់, ផ្ទះសំណាក់ ៤១កន្លែង ស្មើនឹង ៥០៦បន្ទប់, ម៉ូតែល និងប៊ូទិក ០៧កន្លែង ស្មើនឹង ១៥៤ បន្ទប់ ភោជនីយដ្ឋាន និងអាហារដ្ឋាន ៣០កន្លែង ខារ៉ាអូខេ ១២កន្លែង ស្មើនឹង ៥៦បន្ទប់ ម៉ាស្សា ០៤កន្លែង មគ្គុទេសក៍ទេសចរណ៍ចំនួន ៧៥នាក់ ស្រី ០៥នាក់ និងមានក្រុមហ៊ុនវិនិយោគលើវិស័យទេសចរណ៍ ០៣ក្រុមហ៊ុន (អនុញ្ញាតដោយអាជ្ញាធរខេត្ត) ។
- វិស័យគមនាគមន៍ ៖ ប្រវែងផ្លូវក្នុងខេត្តសរុប៖ **៨៩១,៣៧៦គ.ម** ក្នុងនោះផ្លូវក្នុងខេត្តចំនួន **០៨ខ្សែ** ប្រវែង **៥៣០,៥គ.ម** ផ្លូវក្នុងក្រុងចំនួន **៥៩ខ្សែ** ប្រវែង **៦៥.៨៧៦ម** និងផ្លូវលំចំនួន ៣២ខ្សែ ប្រវែង **២៥៥គ.ម** ។ ផ្លូវជាតិលេខ៧៦ ពីស្រុកស្នួល ខេត្តក្រចេះ មកដល់ក្រុងសែនមនោរម្យប្រវែង **១២៧គ.ម** និងពីក្រុងសែនមនោរម្យ ទៅតាអង្គ ស្រុកកូនមុំ ខេត្តរតនគិរី ប្រវែង **១៧២គ.ម** ។ ផ្លូវលេខ៧៥ ពីស្រុកកោះញែក ទៅស្រុកចិត្របុរី ខេត្តក្រចេះ ប្រវែង **១៥០គ.ម**(ផ្លូវដី)។ ផ្លូវច្រកទ្វារព្រំដែនទ្វេភាគី តភ្ជាប់តំបន់ព្រំដែនជាមួយវៀតណាម មានចំនួន ០៣ខ្សែ ប្រវែង **៨៧គ.ម** ។

- វិស័យ ធនធានរ៉ែ និងថាមពល ៖ ក្រុមហ៊ុនវិនិយោគលើវិស័យធនធានរ៉ែសរុបចំនួន ២៤ អាជ្ញាប័ណ្ណ ក្នុងនោះមាន ១២ក្រុមហ៊ុន ស្មើនឹង ១៧អាជ្ញាប័ណ្ណ ជាលក្ខណៈសិប្បកម្ម មាន ០៧អាជ្ញាប័ណ្ណ ។ បច្ចុប្បន្នមានក្រុមហ៊ុន រ៉ូណេសង់ មីណឺរ៉ល ខេមបូឌា លីមីធីត បានធ្វើអាជីវកម្មចម្រាញ់រ៉ែមាសជាផ្លូវការលើកដំបូងចាប់ពីថ្ងៃទី២១ ខែមិថុនា រហូតដល់បច្ចុប្បន្ននេះ ទទួលបានលទ្ធផលដោយចម្រាញ់រ៉ែមាសបានចំនួន ១៨៣៣.១គីឡូក្រាម ។ ស្ថានីយ៍ប្រេងឥន្ធនៈក្នុងខេត្តសរុបចំនួន ៤៣ស្ថានីយ៍ និងប្រេង និងឧស្ម័នឥន្ធនៈមានចំនួន ០៤ស្ថានីយ៍ និងមានទីតាំងសំខាន់ៗជាច្រើនមានអំណោយផលដល់ការសាងសង់វារីអគ្គិសនី ផងដែរ ។

### ❖ ការងារសន្តិសុខ និងសណ្តាប់ធ្នាប់

សភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់ទាំងផ្ទៃក្នុងខេត្ត និងនៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា - វៀតណាម មិនមានអ្វីកើតឡើងគួរឱ្យកត់សម្គាល់ ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសង្គម នោះទេ ទាំងនេះដោយសារ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត អនុវត្តបានយ៉ាងល្អប្រសើរនូវគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ។

### ❖ ការងារក្រុមប្រឹក្សាខេត្ត

ដោយផ្អែកតាមគោលនយោបាយកំណែទម្រង់ស៊ីជម្រៅ ក៏ដូចជាកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងមហាផ្ទៃជាសេនាធិការ ជូនរាជរដ្ឋាភិបាល បានរៀបចំបង្កើតឱ្យមានច្បាប់ស្តីពីការរៀបចំអង្គការ ដែលជាមូលដ្ឋានគតិយុត្តិសម្រាប់កិច្ចកំណែទម្រង់រដ្ឋបាលតាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិ និងបានបង្កើតឱ្យមានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈការបោះឆ្នោតអសកល ដែលយើងបានដឹងរួចមកហើយថា រហូតមកដល់បច្ចុប្បន្ននេះ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានបង្កើតឡើងចំនួន ៣អាណត្តិមកហើយ ។ ក្រុមប្រឹក្សា មានតួនាទីជានីតិបញ្ញត្តិផង និងជានីតិប្រតិបត្តិផង និងត្រូវមានគណនេយ្យភាពជាចម្បង និងដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ សំដៅជានាដល់ការបង្កើននូវតម្លាភាព ប្រសិទ្ធភាព ជំរុញឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ យកចិត្តទុកដាក់សំខាន់លើតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត វិភាជន៍ធនធាន ផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ។

ខេត្តមណ្ឌលគិរី មានប្រធាន និងសមាជិកក្រុមប្រឹក្សា ដូចខាងក្រោម ៖

-ក្រុមប្រឹក្សាខេត្ត មានចំនួន ១៥ នាក់ ស្រី ០៣នាក់ (បោះឆ្នោតអសកល)

-ក្រុមប្រឹក្សាក្រុង-ស្រុក មានចំនួន ៥៩ នាក់ ស្រី ០៨ នាក់ (បោះឆ្នោតអសកល)

-ក្រុមប្រឹក្សាឃុំសង្កាត់ មានចំនួន ១០៧ នាក់ ស្រី ២៣ នាក់ (បោះឆ្នោតសកល)

នៅក្នុងឆ្នាំ២០២១ ក្រុមប្រឹក្សាខេត្តបានចូលរួមក្នុងកម្មវិធីផ្សេងៗសរុបចំនួន ៤៣លើក ថែមទាំងបានបើកកិច្ចប្រជុំរបស់ខ្លួន និងគណៈកម្មាធិការនានាចំនួន ២៩លើក ក្នុងនោះកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាចំនួន ១១លើក ប្រជុំវិសាមញ្ញចំនួន ០២លើក គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសចំនួន ០១លើក គណៈកម្មាធិការលទ្ធកម្មចំនួន ០៦លើក និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារចំនួន ០៩លើក ។ ក្រៅពីនេះ ក្រុមប្រឹក្សាខេត្ត បានចុះតាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងសិក្សាស្វែងយល់អំពីទុក្ខលំបាក និងស្វែងរកដំណោះស្រាយជូនដល់ប្រជាពលរដ្ឋ ។

## ❖ ផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ផែនការវិនិយោគបីឆ្នាំរំកិល និងផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ ដែលមានសំណើគម្រោងពីគ្រប់រដ្ឋបាលឃុំសង្កាត់ ក្រុង ស្រុក ខេត្ត មន្ទីរអង្គភាពជុំវិញខេត្ត ហើយក្នុងនោះ គម្រោងអភិវឌ្ឍន៍ខេត្តមណ្ឌលគិរី សម្រាប់អនុវត្តក្នុងឆ្នាំ២០២១ សរុបចំនួន ១០៧គម្រោង ស្មើនឹងថវិកាចំនួន ៣៨២.០៧៩ លានរៀល ក្នុងនោះ គម្រោងរបស់រដ្ឋបាលខេត្តចំនួន ២៨គម្រោង ស្មើនឹងថវិកាចំនួន ១១.៤៦៩ លានរៀល និង គម្រោងរបស់មន្ទីរ អង្គភាពជុំវិញខេត្តចំនួន ៧៩គម្រោង ស្មើនឹងថវិកាចំនួន ៣៧០.៦១០ លានរៀល ។ ក្រៅពីនេះ គម្រោងអភិវឌ្ឍនរបស់រដ្ឋបាលក្រុង-ស្រុក សម្រាប់ឆ្នាំ២០២១ សរុបមានចំនួន ១៩២គម្រោង ស្មើនឹងថវិកាចំនួន ២៦.១៣២ លានរៀល និងគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលឃុំ/សង្កាត់ សម្រាប់ឆ្នាំ២០២១ សរុបមានចំនួន ៧៦៤ គម្រោង ស្មើនឹងថវិកាចំនួន ១៨៧.២៦៥ លានរៀល ។

## ❖ វេទិកាក្រុមប្រឹក្សាខេត្ត

នៅក្នុងឆ្នាំ២០២១នេះ ដោយសារព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ នៃការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ ទូទាំងប្រទេស និងដោយយោងតាមការណែនាំរបស់ក្រសួងមហាផ្ទៃក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ ក្រុមប្រឹក្សាខេត្តមណ្ឌលគិរី មិនបានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់តាមក្រុង-ស្រុក នោះទេ ។ ទោះបីជា ក្រុមប្រឹក្សាខេត្ត មិនបានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត ក៏ដោយ ក្រុមប្រឹក្សាខេត្ត នៅតែបន្តយកចិត្តទុកដាក់ពិនិត្យ សិក្សា និងក្តាប់នូវសភាពការណ៍ទុក្ខលំបាក និងសេចក្តីកង្វល់របស់ប្រជាពលរដ្ឋ និងស្វែងរកដំណោះស្រាយជូនបងប្អូនប្រជាពលរដ្ឋ តាមរយៈកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងការធ្វើរបាយការណ៍ជូនថ្នាក់ជាតិ ។

## ❖ ការងារផ្តល់សេវាសាធារណៈ តាមយន្តការច្រកចេញចូលតែមួយ

ក្នុងឆ្នាំ២០២១ កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយន្តការដ៏មានប្រសិទ្ធភាពមួយដើម្បីបម្រើប្រជាពលរដ្ឋក្នុងការផ្តល់សេវាសាធារណៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព សមភាព តម្លាភាព និងគណនេយ្យភាព ទប់ស្កាត់អំពើពុករលួយតាមរយៈយន្តការច្រកចេញចូលតែមួយ និងការិយាល័យប្រជា-ពលរដ្ឋខេត្ត។ ចំពោះអង្គភាពច្រកចេញចូលតែមួយ មានតួនាទីភារកិច្ចជាអ្នកផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ដែលមានដាក់តារាងតម្លៃសេវា កំណត់ពេលវេលា ចំណែកការិយាល័យប្រជាពលរដ្ឋ ជាអ្នកតាមដានការផ្តល់សេវា ហើយរាយការណ៍មកក្រុមប្រឹក្សាផ្ទាល់ ក្នុងករណី មានភាពមិនប្រក្រតីណាមួយកើតឡើង ក្រុមប្រឹក្សាខេត្ត ធ្វើការណែនាំ និងជំរុញឱ្យគណៈអភិបាលខេត្ត មានវិធានការដោះស្រាយ ។

ជាក់ស្តែង ចាប់ពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ អង្គភាពច្រកចេញចូលតែមួយ នៃរដ្ឋបាលខេត្ត បានយកចិត្តទុកដាក់ខិតខំប្រឹងប្រែងក្នុងការផ្តល់សេវា ក្នុងនោះ យើងបានទទួលសេវាចំនួន **២ ៨០៣ សេវា** ក្នុងនោះ កំពុងដំណើរការផ្តល់ចំនួន **១ ១៦៩ សេវា** និងបានបញ្ចប់ការផ្តល់ចំនួន **១ ៦៣៤សេវា** ដែលទទួលចំណូលជាទឹកប្រាក់សរុបចំនួន **៥៩៨ ០៧១ ០៥០រៀល** លើវិស័យជំនាញចំនួន១២ បន្ថែមលើសេវារដ្ឋបាល ដែលផ្តល់ដោយរដ្ឋបាលខេត្ត។ ក្រៅពីនេះក្នុងចំណោមរដ្ឋបាលក្រុងស្រុកទាំង៥ មានក្រុង-ស្រុក ចំនួន ៣ហើយ ដែលមានការិយាល័យច្រកចេញចូលតែមួយគឺ នៅក្រុងសែនមនោរម្យ ស្រុកកែវសីមា និងស្រុកកោះញែក ដែលបាន និងកំពុងដំណើរការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ដោយឡែកស្រុកពេជ្រាដា បានសាងសង់រួចរាល់ និងកំពុងរៀបចំបំពាក់សម្ភារសម្រាប់ដំណើរការការងារ និងស្រុកអូររាំង មិនទាន់បានសាងសង់នៅឡើយទេ ។

❖ **ការងារអភិវឌ្ឍធនធានមនុស្ស**

នៅឆ្នាំ២០២១ ក្នុងការអភិវឌ្ឍសមត្ថភាពមន្ត្រីរដ្ឋបាលខេត្ត ក្រុង ស្រុក ដែលជាមន្ត្រីរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាខេត្តមានមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ជាថ្នាលបណ្តុះបណ្តាល បានរៀបចំវគ្គបណ្តុះបណ្តាល និងវគ្គរំលឹកឡើងវិញតាមប្រព័ន្ធអនឡាញ (Zoom) ដោយសារមានការរាលដាល នៃជំងឺកូវីដ-១៩ ក្នុងនោះរួមមាន ៖

- វគ្គការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ខេត្ត និងតាមក្រុងស្រុកទាំង៥
- វគ្គតម្រង់ទិសស្តីពីការគ្រប់គ្រងរដ្ឋបាលក្រុង-ស្រុក
- វគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពអំពីបរិយាប័ន និងសមធម៌សង្គមដល់មន្ត្រីពាក់ព័ន្ធ
- វគ្គបណ្តុះបណ្តាលស្តីពីបែបបទ និងនីតិវិធី នៃការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលក្រុង ស្រុក
- វគ្គបណ្តុះបណ្តាលស្តីពីបែបបទ និងនីតិវិធី នៃការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលខេត្ត និងផ្សព្វផ្សាយអនុក្រឹត្យលេខ៥៦, អនុក្រឹត្យលេខ២៤០ និងសេចក្តីណែនាំលេខ ៧៨៩ ។
- វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងពង្រឹងរបៀបរបបធ្វើការងារមន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

សូមបញ្ជាក់ថា មន្ត្រីរាជការក្នុងខេត្តមណ្ឌលគិរីសរុបចំនួន ២១០០នាក់ ស្រី ៨០៤នាក់ ក្នុងនោះ នៅរដ្ឋបាលខេត្តមានចំនួន ៩៣នាក់ ស្រី ៣២នាក់ នៅពន្ធនាគារខេត្តមានចំនួន ៤១នាក់ ស្រី ០៤នាក់ នៅមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តមានចំនួន ២៨៣នាក់ ស្រី ១៤៤នាក់ នៅរដ្ឋបាលក្រុង ស្រុក មានចំនួន ១៧៤នាក់ ស្រី ៤៣នាក់ និងនៅតាមមន្ទីរអង្គភាព មានចំនួន ១៥០៩នាក់ ស្រី ៥៨១នាក់ ។

ឆ្លងតាមសកម្មភាពកសាងសមត្ថភាពនេះ លទ្ធផលបានបង្ហាញថា មន្ត្រីទាំងថ្នាក់ខេត្ត ក្រុង ស្រុក មានការផ្លាស់ប្តូរ រីកចម្រើនជាបន្តបន្ទាប់នូវផ្នត់គំនិត ឥរិយាបថ និងអាកប្បកិរិយាទទួលខុសត្រូវខ្ពស់ ក្នុងការបំពេញការងារ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ បានកាន់តែល្អប្រសើរ ។

❖ **ការងារគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ និងការងារគណនេយ្យភាពសង្គម**

ជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ បានរៀបចំកិច្ចប្រជុំចំនួន ០៩ លើក និងបានចុះផ្សព្វផ្សាយនៅតាមក្រុងស្រុកទាំង៥ ដែលផ្តោតជាពិសេសលើការសម្របសម្រួលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត និងជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋ ក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធទៅនឹងកិច្ចការស្ត្រី យុវវ័យ និងកុមារ។

ការងារគណនេយ្យភាពសង្គម ក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានគោលបំណងផ្តល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ជាពិសេសក្រុមដែលតំណាងឲ្យផលប្រយោជន៍របស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនានា ក្នុងការចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការលើកកម្ពស់នូវភាពងាយទទួលបានព័ត៌មាន និងការចូលរួមពិនិត្យតាមដានលើការងារថវិកា និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងនោះ ខេត្តមណ្ឌលគិរី បានបើកឱ្យមានការចូលរួមមតិពីក្រុមដែលតំណាងឲ្យផលប្រយោជន៍របស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនានា ម្តងក្នុងមួយឆ្នាំ ដែលក្រុមការងារគណនេយ្យភាពសង្គម បានចុះទៅផ្សព្វផ្សាយដល់មូលដ្ឋានឃុំ-សង្កាត់។

❖ **អំពីសមិទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០២១**

**ការងារសេដ្ឋកិច្ច**

- រដ្ឋបាលខេត្ត បានជំរុញដល់មន្ទីរ អង្គភាពពាក់ព័ន្ធក្នុងការអនុវត្តការងារទទួលបានលទ្ធផលល្អប្រសើរលើការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការងារ ការងារធនធានទឹក និងឧតុនិយម ការងារអភិវឌ្ឍន៍ជនបទ ការងាររ៉ែ និងថាមពល ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ការងារពាណិជ្ជកម្ម ការងារសេដ្ឋកិច្ច ពន្ធដារ គយ និងរដ្ឋាករ និងរតនាគារ និងការងារទេសចរណ៍ ជាដើម។ល។

**ការងារសង្គមកិច្ច**

- រដ្ឋបាលខេត្ត ក៏បានជំរុញដល់មន្ទីរ អង្គភាពពាក់ព័ន្ធក្នុងការអនុវត្តការងារទទួលបានលទ្ធផលល្អប្រសើរលើការងារអប់រំ បណ្តុះបណ្តាល ការងារសុខាភិបាល ជាពិសេស បានយកចិត្តទុកដាក់ខ្លាំងក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ ការងារធម្មការ និងសាសនា ការងារវប្បធម៌ និងវិចិត្រសិល្បៈ ការងារព័ត៌មាន ការងារកិច្ចការស្ត្រី និងកុមារ ការងារផែនការ ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ការងារមុខងារសាធារណៈ និងកិច្ចការងារមនុស្សធម៌ផ្សេងៗជាដើម។ល។

**ការងារគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងបម្រែបម្រួលអាកាសធាតុ**

- ជំរុញលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ការងារគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន និងអនាម័យ ការងារសាធារណការ ដឹកជញ្ជូន និងកែលម្អសោភ័ណ្ឌភាព ។

**ការងារគ្រប់គ្រងរដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់**

- ជំរុញដល់បណ្តាកងកម្លាំងប្រដាប់អាវុធ រដ្ឋបាលក្រុង ស្រុក ក្នុងការចូលរួមសហការអនុវត្តការងារថែរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ជូនដល់ប្រជាពលរដ្ឋ ជាពិសេស ការងារសន្តិសុខផ្ទៃក្នុងខេត្ត និងការងារសន្តិសុខនៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសវៀតណាម ។ នៅក្នុងការងារគ្រប់គ្រងរដ្ឋបាល និងសន្តិសុខ រដ្ឋបាលខេត្ត បានផ្តោតសំខាន់ និងយកចិត្តទុកដាក់ខ្ពស់លើការងារសំខាន់ៗដូចជា ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍ ការងារគ្រប់គ្រងច្រកទ្វារព្រំដែន ការងារគ្រប់គ្រងជនអន្តោប្រវេសន៍ ការងារអត្តសញ្ញាណកម្ម ការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងការងារគ្រប់គ្រងទណ្ឌិត និងពិរុទ្ធជន ដែលកំពុងជាប់ឃុំនៅក្នុងពន្ធនាគារ ជាដើម។ល។

ចំពោះទិន្នន័យលំអិត ដូចមានរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តមណ្ឌលគិរី ជូនភ្ជាប់មកជាមួយស្រាប់ ។

❖ **ការងារកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ**

អនុវត្តតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើកំណែទម្រង់កាន់តែស៊ីជម្រៅលើប្រព័ន្ធអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ តួយ៉ាងការកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាលក្រុង-ស្រុក រួមទាំងការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋបាលខេត្តមណ្ឌលគិរី សម្រេចបានយ៉ាងជោគជ័យលើការងារធ្វើសមាហរណកម្ម និងការរៀបចំបុគ្គលិកនៅតាមការិយាល័យ និងអង្គភាពនានាចំនួន ១៧៧នាក់ ស្រី ៥៤នាក់ ទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក។

ជាមួយគ្នានេះផងដែរ ក្រសួងសុខាភិបាល តាមរយៈលិខិតលេខ ០៥៩ សនប ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ បានប្រកាសផ្ទេរបុគ្គលិកសុខាភិបាលចំនួន ២៩០នាក់ ស្រី ១៤៨នាក់ មកឲ្យរដ្ឋបាលខេត្ត ជាអ្នកចាត់ចែង គ្រប់គ្រង និងប្រើប្រាស់ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលខេត្ត ។

ក្រៅពីនេះ បច្ចុប្បន្ននេះ រដ្ឋបាលខេត្ត បានចូលរួមយ៉ាងសកម្មនៅក្នុងការអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅពង្រឹងការប្រើប្រាស់កញ្ចប់ថវិកាជាតិឱ្យបានចំគោលដៅ និងមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។

### ❖ ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

- អនុវត្តការងារដោយបន្តប្រើប្រាស់យន្តការដែលមានស្រាប់ គឺគណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ខេត្តមណ្ឌលគិរី និងបានជំរុញដល់គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង-ស្រុក ក៏ដូចជា គណៈកម្មការកូវីដ-១៩ ធ្វើការផ្សព្វផ្សាយទៅដល់ឃុំ-សង្កាត់ និងទីតាំងសំខាន់ៗ ដូចជាទីប្រជុំជនតាមចំនួនដែលបានកំណត់ ដោយធ្វើការផ្សព្វផ្សាយតាមរយៈការចាក់ផ្សាយតាមទូរទស្សន៍ Online ចាក់ផ្សាយតាមវិទ្យុជាតិខេត្តមណ្ឌលគិរី វិទ្យុបាយ័នផ្សាយបន្តផ្ទាល់ តាមវេបសាយមន្ទីរព័ត៌មានខេត្ត ផេក វេបសាយ និងបណ្តាញទំនាក់ទំនងសង្គមរបស់រដ្ឋបាលខេត្ត ការចាក់ឧឃោសនស័ព្ទ ការផ្សព្វផ្សាយតាមបណ្តាញសង្គម បិទផ្សាយផ្ទាំងរូបភាព នៅគ្រប់បណ្តាឃុំ-សង្កាត់ ទាំង២១ និងភូមិចំនួន ៩២ភូមិ ។
- ថ្នាក់ដឹកនាំ មន្ត្រីរាជការខេត្តមណ្ឌលគិរី បានចូលរួមបរិច្ចាគប្រាក់បៀវត្ស និងជាថវិកាផ្ទាល់សម្រាប់ចូលរួមទប់ស្កាត់ និងទិញវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនរាជរដ្ឋាភិបាលកម្ពុជា ផងដែរ ។
- បានបំផុស និងជំរុញដល់មន្ត្រីរាជការ យុវជន ចូលរួមយ៉ាងសកម្ម ក្នុងការចុះអប់រំ ណែនាំ និងផ្សព្វផ្សាយនៅតាមភូមិ ឃុំ ស្រុក ក្នុងការចូលរួមបង្ការ ទប់ស្កាត់ ការរីករាលដាលជំងឺកូវីដ-១៩ ។
- បានត្រៀមរៀបចំទីតាំងធ្វើចត្តាឡីស័កសម្រាប់បងប្អូនប្រជាពលរដ្ឋ ដែលបានធ្វើចំណាក ស្រុក ជាពិសេស បងប្អូនប្រជាពលករ ដែលវិលត្រលប់មកពីប្រទេសថៃ និងប្រទេសវៀតណាម ។
- បានចូលរួមកៀងគរមូលនិធិ ថវិកា សម្ភារៈ និងម្ហូបអាហារ ក្នុងការចែកជូនប្រជាពលរដ្ឋ ដែលងាយរងគ្រោះដោយសារជំងឺកូវីដ-១៩ ។
- បានសហការល្អជាមួយភាគីវៀតណាម ក្នុងការសហការបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាល ជំងឺកូវីដ-១៩ នៅតាមព្រំដែនប្រទេសទាំងពីរ ដែលខេត្តមណ្ឌលគិរី មានព្រំប្រទល់ជាប់ជាមួយបណ្តាខេត្តបីរបស់វៀតណាម រួមមាន ខេត្តដាក់ឡាក់ ខេត្តដាក់ណុង និងខេត្តប៊ិញភឿក ។
- គិតមកត្រឹមថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២នេះ ទូទាំងខេត្តមណ្ឌលគិរី មានអ្នកឆ្លងជំងឺកូវីដ-១៩ សរុបចំនួន ២ ៦៩២នាក់ ស្រីចំនួន ១ ៤៨៦នាក់ ក្នុងនោះ អ្នកជាសះស្បើយចំនួន ២៦៥៦នាក់ ស្រីចំនួន ១ ៤៧៦ នាក់ អ្នកកំពុងសម្រាកព្យាបាលនៅផ្ទះចំនួន ៣៦នាក់ ស្រីចំនួន ១០នាក់ និងអ្នកស្លាប់មានចំនួន ១២នាក់ ស្រី ០៩ នាក់ ។
- សរុបការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ទូទាំងខេត្ត ចាប់ពីអាយុ ៥ឆ្នាំឡើង ផែនការចាក់សរុបចំនួន ៩៩,២៥៩នាក់ ក្នុងនោះ ចាក់ដូសទី១ បានចំនួន ១០៣ ៧៩៣នាក់ ស្មើនឹង ១០៤.៥៧% , ចាក់

ជួសទី២ បានចំនួន ៦៤ ០៣៨នាក់ ស្មើនឹង ៦៤.៥២% , ចាក់ជួសទី៣ បានចំនួន ៣២ ០៧៦នាក់ ស្មើនឹង ៣២.៣២% និងមិនទាន់បានចាក់ចំនួន ៤ ៥៣៥នាក់ ស្មើនឹង ៤.៥៧% ។

សរុបជារួមមក នៅក្នុងខេត្តមណ្ឌលគិរី ក្រោមការដឹកនាំរបស់រដ្ឋបាលខេត្តមណ្ឌលគិរី ដែលមានក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត រួមនឹងការគាំទ្រជាចាំបាច់របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តមណ្ឌលគិរី ដែលដឹកនាំដោយ ឯកឧត្តម **ខឹ ចន្ទ្រផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានធ្វើឲ្យខេត្តមណ្ឌលគិរី មានការអភិវឌ្ឍរីកចម្រើនឡើងលើគ្រប់វិស័យ។ ក្នុងនោះ ការងារគ្រប់គ្រងរដ្ឋបាល ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការងារកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ច ការងារផ្តល់សេវាសាធារណៈ ការងារគ្រប់គ្រងព្រំដែន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការអភិវឌ្ឍសមត្ថភាព ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ការអភិវឌ្ឍវិស័យឯកជន វិស័យការងារ និងវិស័យបណ្តុះបណ្តាល ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងគ្រោះមហន្តរាយ ការគ្រប់គ្រងដីសាធារណៈរបស់រដ្ឋ ការដោះស្រាយទំនាស់ដីធ្លី ក៏កំពុងត្រូវបានជានា និងមានការអភិវឌ្ឍរីកចម្រើនគួរឲ្យកត់សម្គាល់ ធ្វើឱ្យខេត្តទាំងមូលមានការប្រែមុខមាត់ថ្មី ព្រមទាំងបានលើកកម្ពស់ស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពប្រសើរឡើង ពីមួយឆ្នាំទៅមួយឆ្នាំ ។

ទន្ទឹមនឹងនេះដែរ ចំពោះរដ្ឋបាលខេត្ត ក៏បានទទួលនូវការកោតសសើរ និងវាយតម្លៃខ្ពស់ ពីក្រសួងមហាផ្ទៃ ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកគ្រប់គ្រង និងចាត់ចែងអនុវត្តកិច្ចការនៅមូលដ្ឋាន ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឲ្យមានការអភិវឌ្ឍ រីកចំរើន គួរឲ្យកត់សម្គាល់ លើការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាល ។

ក្នុងនាមរដ្ឋបាលខេត្ត ខ្ញុំសូមប្តេជ្ញាថា នឹងខិតខំបន្តអនុវត្តនូវគោលនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ និងដំណាក់កាលបន្តបន្ទាប់ទៀត ដែលបានរួមចំណែកដ៏ធំធេងក្នុងការរក្សាបាននូវសន្តិសុខស្ថេរភាពនយោបាយ សង្គម និងបង្កើនគុណ-ភាព នៃការផ្តល់សេវាប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព មានការអភិវឌ្ឍប្រកបដោយចីរភាព បង្កើតបាននូវបុរេល័ក្ខខ័ណ្ឌចាំបាច់ និងបរិស្ថានអនុគ្រោះ សម្រាប់ការប្រែក្លាយខ្លួនឲ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ៕

**ជាទីបញ្ចប់** ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរចំពោះ សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ សូមថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម **សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំង សម្តេចព្រះមហាក្សត្រី នរោត្តម **មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គទាំងទ្វេ មានព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ដ៏ត្រជាក់ត្រជុំដល់ប្រជារាស្ត្ររបស់ព្រះអង្គ និងសូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសន្និសីទទាំងមូល សូមបានសមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ !**